ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ :..០៤១..សប្រក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ស្ថានភាពពលរដ្ឋភៀសសឹក ផលប៉ះពាល់លើតំបន់ស៊ីវិល
## គិតពីម៉ោង៦ព្រឹក ថ្ងៃទី១៣ ដល់ម៉ោង៦ព្រឹក ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៦

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា សូមជម្រាបជូនថា ចាប់តាំងពីបទឈប់បាញ់រវាងកម្ពុជា និងថៃ ចូលជាធរមាន កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥មក ភាគីទាំងសងខាងពុំបានផ្ទុះអាវុធដាក់គ្នានោះឡើយ។ ក៏ប៉ុន្តែ កម្ពុជាបានតាមដាន និងកត់ត្រាទុកនូវសកម្មភាពមិនស្មោះត្រង់ជាបន្តបន្ទាប់របស់ភាគីថៃ។ **ក្រសួងមហាផ្ទៃ** សូមជូនបច្ចុប្បន្នភាពសភាពការណ៍ជារួម គិតពីម៉ោង៦ព្រឹក ថ្ងៃទី១៣ ដល់ម៉ោង៦ព្រឹក ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៦ ដូចខាងក្រោម៖

**១-ស្ថានភាពពលរដ្ឋភៀសសឹក៖** មានពលរដ្ឋភៀសសឹក១.១០២នាក់បន្ថែមទៀត បានបន្តវិលត្រឡប់ទៅលំនៅឋានវិញ។ ដូច្នេះ ក្នុងចំណោមពលរដ្ឋភៀសសឹកសរុបជាង៦សែន៤ម៉ឺននាក់ មានជាង៥សែន៧ម៉ឺននាក់ ឬជិត ៨៨% បានវិលត្រឡប់ទៅលំនៅឋានវិញ។ នៅមានពលរដ្ឋចំនួន៧៧.២៧៤នាក់ទៀត (ស្ត្រី៤០.៦៨៩នាក់ និងកុមារ២៦.២០៥នាក់) ពុំទាន់អាចវិលទៅលំនៅឋានវិញ។

**២-ការបន្តផ្អាកសេវាសាធារណៈជាមូលដ្ឋាន៖ ខេត្តឧត្តរមានជ័យ** មានសាលារៀន១៤ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព៧ បន្តផ្អាក។ **ខេត្តបន្ទាយមានជ័យ** មានសាលារៀន៥ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១ បន្តផ្អាក។ **ខេត្តព្រះវិហារ** មានសាលារៀន២៩ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១៤ នៅបន្តផ្អាក។

**៣-ការខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖** គិតចាប់ពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥មក ការខូចខាតទ្រព្យសម្បត្តិសាធារណៈ និងឯកជន ពុំទាន់មានរបាយការណ៍ថ្មីបន្ថែមលើករណីដែលក្រសួងបានកត់ត្រាទុកនៅឡើយទេ។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** គាំទ្រពេញទំហឹងលើការតវ៉ាដាច់អហង្ការរបស់រាជរដ្ឋាភិបាលចំពោះសកម្មភាពមិនស្មោះត្រង់ជាបន្តបន្ទាប់របស់ភាគីថៃ ជាក់ស្តែងថ្មីៗនេះទៀត បានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធស៊ីវិល និងអគាររដ្ឋបាល ស្ថិតក្នុងស្រុកថ្មពួក និងជីកប្រឡាយ សាងសង់ផ្លូវ ព្រមទាំងចាក់ដីលុបស្រះទឹក នៅភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ សកម្មភាពនេះបានដើរផ្ទុយពីខ្លឹមសារនៃសេចក្តីប្រកាសរួម កិច្ចប្រជុំពិសេសលើកទី៣នៃគណៈកម្មាធិការព្រំដែនទូទៅ(GBC) ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ជាពិសេសគោលការណ៍គ្រឹះនៃធម្មនុញ្ញអាស៊ាន និងធម្មនុញ្ញអង្គការសហប្រជាជាតិ។ ក្នុងន័យនេះ ជារឿងចាំបាច់ ដែលសាធារណជនជាតិ និងអន្តរជាតិ ត្រូវដឹងច្បាស់ពីជំហរកម្ពុជា ជាពិសេស **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានសង្កត់ធ្ងន់ថា **ព្រំដែនកម្ពុជា-ថៃ គឺជាព្រំដែនអន្តរជាតិរវាងរដ្ឋ និងរដ្ឋ និងដែលរាជរដ្ឋាភិបាលប្តេជ្ញាការពារអធិបតេយ្យ បូរណភាពទឹកដី និងប្រជាជន ទាំងបច្ចុប្បន្ន និងអនាគត ដោយផ្អែកលើច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងដែលមានស្រាប់របស់ភាគីទាំងពីរ ដោយមិនទទួលស្គាល់ដាច់ខាត ការកាន់កាប់ទឹកដីគ្រប់រូបភាពតាមរយៈការប្រើកម្លាំងខុសច្បាប់។**

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវជនរួមជាតិរួបរួមគាំទ្រ និងជឿជាក់លើរាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាព្រំដែនតាមគោលការណ៍សន្តិវិធី ច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងជាធរមាន និងសូមរក្សាស្មារតីរួមមួយថា **ជម្លោះទឹកដីនេះពិតជាបង្កការឈឺចាប់ ប៉ុន្តែយើងមិនត្រូវជ្រួលច្របល់ដោយសារការឈឺចាប់នេះជាដាច់ខាត ផ្ទុយទៅវិញគឺត្រូវប្រែក្លាយការឈឺចាប់នេះឱ្យទៅជាភាពរឹងមាំនៃជាតិ និងប្រជាជនយើង។**

ថ្ងៃសៅរ៍ ១២រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៦